# ស័ន្ធសិល្បជ័យ

## ភាគទី៩

លុះក្រោយមក ក្សត្រីទាំងប្រាំមួយ ក៏ឡើងគាល់ស្ដេចទៀត ដោយទូលថា: "ឥឡូវនេះណា ដោយហោរាទាយដូច្នោះហើយ ទាំងប្រជារាស្ត្រ ទាំងមន្ត្រិសុទ្ធសឹងតែងសុំឲ្យព្រះអង្គបំបរបង់បុត្រ ព្រោះថាខ្លាចនឹងកើតទុក្ខភ័យនៅប្រាំពីរថ្ងៃទៀតនេះ សូមព្រះអង្គទ្រង់ព្រះចិន្ដាផង..."។ អង្គក្សត្រសេនាកុត្តរាជសណ្ដាប់រួច ក៏ព្រួយក្នុងព្រះហឫទ័យអាល័យបុត្រពេកណាស់ តែនឹងធ្វើម្ដេច បើកម្មកមកាត់ផ្ដាច់ ឲ្យត្រូវបំបរបង់ទាំងម្ដាយទាំងកូនរស់រងទុក្ខកណ្ដោចកណ្ដែងយ៉ាងនេះ។ ព្រះអង្គសេនាកុត្តរាជ ទ្រង់យាងចូលក្រឡាបន្ទំពិលាបសោយសោកអាណិតអាល័យបុត្រ រហូតសន្ធប់បាត់ស្មារតី ស្រីស្នំទាសាទាសីឃើញដូច្នោះ ក៏យកទឹកមកប្រោះព្រំ។ លុះដឹងព្រះកាយឡើងវិញ ក៏នៅតែសោយសោកនឹកអាណិតបុត្រទៀត។

កាលនោះដែរ អស់មហេសីទាំងប្រាំមួយបានប្រើឲ្យគេរួសរាន់បណ្ដេញអគ្គមហេសីបទុមានិងកេសរបុប្ផាឲ្យបីបុត្រចាកចេញពីរាជវាំង។ ក្សត្រីបទុមាបានយាងទៅគាល់ព្រះស្វាមីនាងទួញសោកបោកប្រាណឱបព្រះបាទាទូលថា:

ទោសអ្វីខ្ញុំផ្ដាំផ្ដង ព្រះបាទបងពុំមេត្តា
កូនកើតនឹងនរណា ក៏ព្រះអង្គមិនប្រណី។

ព្រះអង្គសេនាកុត្តរាជទ្រង់ស្ដាប់រួច ទ្រង់មានបន្ទូលថា: "ឱមាសបងអើយ នាងពុំមានទោសពៃរ៍អ្វីទេ កូនសោតក៏រឹតតែគ្មានទោស តើឲ្យបងធ្វើម្ដេច បើហោរទាំងនោះទាយដូច្នេះ បងមិនស្អប់នាងទេ ព្រោះថានាងមានមារយាទល្អគាប់ជាងគេ តែបើនឹងទុកខ្លាចក្រែងមានទោសដល់នគរ ប្រជារាស្ត្រ ដូច្នេះបើបុណ្យបានសាងរួមគ្នាពីបុព្វមានមែននោះនិងបានជួបវិញរួមបុត្រផង"។

ព្រះអង្គសេនាកុត្តរាជសោយសោកយ៉ាងខ្លាំងរហូតសន្ធបបាត់ស្មារតី អស់ទាំងរាជទេពីយល់ដូច្នោះ ក៏លើកព្រះរាជាទៅក្រឡាបន្ទំ...។ ចំណែកបទុមាសោយសោកាហើយនិយាយថា: "ឱគេបំភ័យបំភ្ញាត់ទាយកូនអញហើយ"។ ទើបនាងថ្វាយបង្គំលាអង្គក្សត្រ

អត្ថបទដោយ៖ មាស សុភាព

ស្វាមី វិលមកប្រាសាទវិញ នាងទួញអាឡោះអាល័យស្រណោះវិមានស្រីស្នំក្រមការ ស្រីស្រីង្គារ គិតថា: ឱ!ហេតុកម្មវេរាអញឲ្យទុក្ខដល់បុត្រយ៉ាងនេះ៖

ឱមាសថ្លើមប្រមាត់ យើងនឹងព្រាត់ពីសីមា
ពុំយល់ព្រះបិតា ពីថ្ងៃនេះទៀងទៅហើយ។

ឱមានតែកេសរបុប្ផា និងកូនប៉ុណ្ណោះ ដែលត្រូវទៅជាមួយម្ដាយ។ ពួកស្រីស្នំទាំងអស់យល់ក្សត្រីមានទុក្ខ ក៏យំរៀបរាប់ថា:

ឱម្ចាស់ថ្លៃសប្បុរស ទោះយើងខុសប៉ុន្មានក្ដី
ព្រះអង្គគួរប្រណី អត់ទោសយើងពុំក្រោធា។

ឥឡូវត្រូវប្រាសព្រាតអង្គម្ចាស់ហើយ សូវស្លាប់ទៅល្អជាងរស់នៅទូលទុក្ខ...។ ក្សត្រីបទុមា និងកេសរបុប្ផាយល់ពួកស្រីស្នំកើតទុក្ខដូច្នេះ រឹតតែកើតទុក្ខទ្វេរឡើង សោយសោករហូតសន្ទប់បាត់ស្មារតី ពួកស្រីស្នំឃើញក៏យកទឹកមកផ្ដិតព្រះភក្ត្រឲ្យបានដឹងព្រះកាយឡើងវិញ...។ ចំណែកអស់រាជទេពីទាំប្រាំមួយដឹងថា បើមិនព្រមចេញទេនោះ ត្រូវអូសដៃទម្លាក់ពីលើមក...។ កាលនោះអស់ទាហាន បានប្រើពាក្យមិនគប្បីចំពោះក្សត្រីតែបទុមាក្សត្រី ប្រាប់ថានឹងចរចេញទៅ បន្ទាប់ពីរៀបចំប្រដាប់ប្រដារួចៗ លុះរៀបចំរួចហើយ បទុមាបានឲ្យកេសរបុប្ផាស្ពាយកញ្ជើមាសដែលវេចខ្ចប់ រួចពសីហ៍បុត្រ និងកាន់ខ្យងស័ង្ខចំណែកនាងបីព្រះពោធិសត្វចុះចាកពីប្រាសាទ។

បទុមា និងកេសរបុប្ផាបានចាកចេញពីរាជវាំង ធ្វើដំណើរកាត់ព្រៃព្រឹក្សារហូតដល់និគ្រោធមួយ នាងបានចូលស្នាក់អាស្រ័យក្រោមព្រះជ្រៃ នាងដាក់បុត្រចុះ ហើយនាងគង់សម្រាកកាយ...។

ព្រះសុរិយាអស្ដង្គត ព្រះចន្ទយាងបំភ្លឺរាត្រី ក្នុងរាត្រីនោះដែរជាថ្ងៃពេញបូណ៌មី ព្រះចន្ទជះពន្លឺភ្លឺថ្លាយ៉ាងស្រទន់ សត្វបក្សាបក្សីឆ្លើយឆ្លងកងរំពងពេញព្រៃ បទុមជាយាឮសម្លេងសត្វយំ ក៏ពិលាបនឹកស្រណោះដល់ប្រាសាទវិមានដែលធ្លាប់រស់នៅសុខសាន្ត។ ពេលនោះមានតែឆាយាព្រះជ្រៃនិគ្រោធជាទិព្វប្រាសាទ មានដីជាគ្រឹះបន្ទំហើយ...នាងគិតថា: "ឱអញអើយ! គិតទៅហេតុតែកម្មវេរាឲ្យប្រាស់ព្រាត់យ៉ាងនេះ អាសូរបុត្រនៅតូចណាស់មិនគួរឡើយបិតាមិនគិតឈ្វេងយល់ បែរជាមកបំបរបង់សោះ..."។

អត្ថបទដោយ៖ មាស សុភាព

នាងបទុមាលើកបុត្របីថ្នមថើបអង្អែលពោលថា:

ឱមាសថ្ងៃម្ដាយអើយ　　កើតមកហើយគួរនឹងស្កល់
ក្បែមក្សាន្តនាមណ្ឌល　　ប្រាង្គប្រាសាទសុខសប្បាយ។
ឥឡូវកម្មកូនភ្ញា　　ឯងឲ្យឃ្លាឃ្លាតឋានហើយ
ព្រលឹងមាសម្ដាយអើយ　　សមលំបាកស្ងួនម្ដាយក្រៃ។

ដោយបុណ្យបារមីព្រះពោធិសត្វ ទើបទេវតាទាំងឡាយមកជួយថែរក្សាកុំឲ្យមានសត្វមកយាយីបានឡើយ។ ហើយក៏បានធ្វើឲ្យក្ដៅដល់ព្រះឥន្ទ្រ ស្ដេចទ្រង់បើកទិព្វចក្ខុមើលយល់ថា ស័ង្ខសិល្បជ័យចំណេរក្រោយទៅ នឹងត្រាស់ជា "ព្រះពុទ្ធ" ដូច្នេះអញគួរជួយបំពេញបារមីឲ្យបានដូចក្ដីប្រាថ្នា។ គិតស្រេចហើយ ព្រះឥន្ទ្រទ្រង់មានបន្ទូលថា: "ហៃពិស្ណុការ ចូរហោះទៅសាងប្រាសាទប្រណីតមួយថ្វាយព្រះពោធិសត្វ" ព្រះពិស្ណុការទទួលរាជបញ្ជាហើយ ទ្រង់ហោះមកសាងប្រាសាទយ៉ាងល្អប្រណីតគ្មានប្រដូចឡើយ។ និម្មិតដើមឈើហូបផ្លែមានដូចជា ដើមគូលែន ពុទ្រា ខ្វិត មាក់ប្រ៉ែន និងដើមឈើជាច្រើនមុខដុះតម្រៀបជាជួរ និងហៅអស់កូនទេវតា មកចាំលេងបន្ទែងជាមួយព្រះពោធិសត្វ និងមានភ្លេងចាំប្រគំថ្វាយជារៀងរាល់ថ្ងៃ...។

លុះរៀបចំរួចហើយ ព្រះពិស្ណុការក៏ហោះទៅឋានទិព្វវិញ។ ចំណែកបទុមា និងកេសរបុប្ផា លុះព្រឹកព្រាងហើយក៏សំពះលាអស់រុក្ខទេវតាថែរក្សាទីនោះ លើកបុត្របីធ្វើដំណើរទៅមុខទៀត កាត់ព្រៃព្រឹក្សាជ្រលងដងអូរ។ ដោយបុណ្យបារមីព្រះពោធិសត្វ ទើបមានបក្សាបក្សី ម្រឹគីម្រឹគា ហែហមជាមួយជាច្រើន...មានទាំងសត្វបក្សាធំតូចហើរបាំងជាម្លប់មិនឲ្យត្រូវថ្ងៃផង ដោយយល់ដូច្នោះបទុមាទួញសោកពោលថា: "នេះហេតុហៅបុណ្យកូនដែលល្អត្រកាលគ្មានប្រៀប មិនគួរឡើយព្រះអង្គបែរបំបរបង់ដូច្នេះទេ..."។

បទុមា និងកេសរបុប្ផា ត្រាច់ក្នុងព្រៃជ្រៅរហូតទៅដល់ទីឋានមណ្ឌលដ៏ល្អត្រកាលដូចទេវតានិម្មិត។ បទុមាគិតថា "ឱទីស្ថានដ៏ល្អវិសេសនេះ ជារបស់នរណាទៅ តើជារបស់គ្រុឌឬយក្សទៅ មើលចុះមានទាំងសព្វគ្រប់ប្រដាប់ទាំងអស់ សូម្បីតែដើមឈើ ក៏ដុះរៀបរយល្អដែរ"។ ក្សត្រទាំងពីរ ក៏ចូលទៅដល់មណ្ឌលនោះ ទើបយល់ថាជាឋានទេវតានិម្មិតច្បាស់ ព្រោះមានទាំងរោងរាជសីហ៍ ហើយគ្រប់ទីកន្លែងទាំងអស់សុទ្ធតែល្អប្រណីត

អត្ថបទដោយ៖ មាស សុភាព

នាងបីបុត្រចូលទៅក្នុងមណ្ឌលបេះផ្លែផល្លាសោយ។ លុះចូលដល់ក្នុងមណ្ឌលក៏មានទេវតាមកគាល់ និងប្រគំភ្លេងថ្វាយជារៀងរាល់ថ្ងៃមិនដែលខានឡើយ...។

រយៈពេលប្រាំពីរឆ្នាំបានកន្លងផុតទៅយ៉ាងឆាប់រហ័ស បុត្របទុមាបានចម្រើនធំមានរូបរាងល្អប្រពៃ ប្រៀបបាននឹងព្រះឥន្ទ្រសួគ៌ា ចំណែករាជសីហ៍ក៏ចម្រើនវ័យដែរ ស័ង្ខសិល្បជ័យតួអង្គព្រះពោធិសត្វធំដឹងក្ដី យល់តែមាតាទាំងពីរមិនឃើញមាននរណាសោះ ក៏ក្រាបបង្គំទូលសួរមាតាថា: "ហេតុអ្វីឋាននេះពុំមានមនុស្សដទៃ ឃើញតែមាតាទាំងពីរដូច្នេះ?" បទុមាឮបុត្រសួរដូច្នោះ ក៏ឱបបុត្ររួចវាចារថា: "កូនអើយ! ស្ដាប់ម្ដាយណា បិតារបស់បុត្រព្រះនាមសេនាកុត្តរាជ សោយរាជ្យនៅបញ្ចាលនគរ ទ្រង់មានឫទ្ធិអំណាចខ្លាំងលើសក្សត្រនានា។ ទ្រង់មានមហេសីប្រាំពីរអង្គ រួមទាំងមាតាផង សុទ្ធតែមានបុត្រម្នាក់មួយអង្គ ដោយបុត្រកើតមកមានកាន់ស័ង្ខសិល្បជ័យនៅដៃដូច្នេះ គេខ្លាចបុត្រដណ្ដើមរាជ្យអំណាចពីកូនគេ ទើបគេឲ្យហោរាទាយបំភ័យ ហើយឲ្យបិតាបំបរបង់យើងមកទីនេះ បិតាមានក្ដីករុណាណាស់ តែក៏មិនអាចទប់ទល់នឹងពាក្យញុះញង់របស់គេបានឡើយ"។ រាជកុមារបានស្ដាប់មាតារៀបរាប់ហើយ ក្នុងព្រះទ័យកើតទុក្ខឥតល្ហែ ក៏ក្រាបបង្គំមាតាចេញទៅលេងតែឯកឯង ពេលខ្លះក៏សាកល្បងថ្ងៃងសរសិល្ប៍ផង...។

យើងស្ទេះត្រឹមនេះមិននិយាយ សូមងាកមកមើលអ្នកថ្មើរព្រៃម្នាក់ បានធ្វើដំណើរកាន់ធ្នូនៅដៃស្វែងរកម្រឹគ លុះដើរតាមដានម្រឹគយូរទៅ ក៏បានទៅដល់ទីលំនៅព្រះស័ង្ខសិល្បជ័យ...។ ព្រានយល់មណ្ឌលទិព្វថ្ងៃ ព្រានភិតភ័យគិតថា: "ឱតើនរណាអេះ! មកតាំងឋាននៅទីនេះអស្ចារ្យណាស់ ប្រៀបបានដែនពណ្ណរាយ តើជាអ្នកមានបុណ្យឬ? ពេលនេះបើអញចូលទៅ ក្រែងគេឃើញអញជាព្រាន គេចាប់អញកាត់សិរសាប្រល័យចោល បើដូច្នេះអញគួរលាក់ខ្លួនលបមើលវិញ"។

គិតស្រេចព្រាន ក៏លបចូលទៅអែបប្រាសាទដើម្បីលបមើល ហើយក៏បានឃើញរាជកុមារ ក្សត្រីបទុមា កេសរបុប្ផា និងរាជសីហ៍ ព្រានបានឃើញដូច្នោះក៏គិតថា: "ឱនេះជាមណ្ឌលនាងបទុមាទេតើ អញស្មានថាជារបស់នរណា តែថានាងសុទ្ធតែស្រី ហេតុអ្វីក៏មានប្រាសាទស្អាតម៉្លេះ ឱនេះប្រហែលជាកូននោះជាអ្នកមានបុណ្យពិតប្រាកដហើយ ទើបទេវតាមកនិម្មិតឲ្យដូច្នេះ អញគិតស្មានថានាងទៅណាបាត់ហើយ តាមពិតមកនៅ

អត្ថបទដោយ៖ មាស សុភាព

សោយសុខទីនេះសោះ អញគួរតែយករឿងនេះទៅទូលក្សត្រីទាំងប្រាំមួយអង្គឲ្យបានជ្រាប"។

គិតស្រេច ព្រានចង្រ្វែសាមាន្យក៏ចាកចេញពីទីនោះ ហើយខិតខំធ្វើដំណើររយៈពេលប្រាំពីរថ្ងៃទើបដល់នគរ។ ហើយក៏ម្ទីម្នាឡើងគាល់ក្សត្រីទាំងប្រាំមួយអង្គា ទូលពីដំណើររឿងដែលខ្លួនបានឃើញ។ ក្សត្រីទាំងប្រាំមួយស្ដាប់ហើយមានបន្ទូល "បើដូច្នោះយើងគួររកមធ្យោបាយដើម្បីប្រល័យឲ្យបាន"។ (ព្រានទូលតប) "មិនបានទេ! ព្រោះថាទីនោះមានទេវតាថែរក្សាល្អណាស់ គ្មានសត្រូវណាទៅបៀតបៀនបានឡើយ"។

**(សូមរង់តាមដានរឿង ស័ង្ខសិល្បជ័យ ភាគទី៦ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព